# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Dec-2014, 15:22
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់ នួន ជា សុំដាក់សារណាបន្ថែមនៅលើបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា:**

សុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
លីវ សុវណ្ណា
Doreen CHEN
Joshua ROSENSWEIG
Xiaoyang NIE

**ចម្លងជូន:**

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

អនុលោមតាមមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") តទៅនេះសូមដាក់សំណើសុំដាក់សារណាបន្ថែមទៅលើបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១ ("បណ្តឹងសាទុក្ខ")៖

១. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់បណ្តឹងជិតចិត្តទៅកាន់អង្គជំនុំជម្រះពិសេសដើម្បីស្នើសុំដកចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម យូរ ឧត្តរា និង ចៅក្រម Jean-Marc Lavergne ទាំងអស់ចេញពីដំណើរការនីតិវិធីបន្តទៀតប្រឆាំងនឹងលោក នួន ជា[1]។ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អង្គជំនុំជម្រះពិសេសបានបដិសេធបណ្តឹងនេះ និង បណ្តឹងស្រដៀងគ្នានេះដែរ របស់មេធាវីការពារក្តី ខៀវ សំផន ("សេចក្តីសម្រេច") ដោយមតិភាគច្រើន ៤ ទល់នឹង ១ ដែលចៅក្រម Rowan Downing មានមតិជំទាស់[2]។ អង្គជំនុំជម្រះពិសេសបានណែនាំថា សម្អាងហេតុទៅលើសេចក្តីសម្រេចដោយមតិភាគច្រើន និង មតិជំទាស់ នឹងត្រូវជូនដំណឹងដល់ភាគីជាភាសា "ខ្មែរ អង់គ្លេស និង បារាំង" នៅពេលដែលឯកសារ [ទាំងបីភាសា] ត្រូវបានបញ្ចប់"[3]។

២. មេធាវីការពារក្តីមានបំណងយោងជាលម្អិតទៅលើសម្អាងហេតុនៃសេចក្តីសម្រេចនេះ និងជាពិសេសមតិជំទាស់របស់ចៅក្រម Downing នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ដែលនឹងត្រូវដាក់នៅថ្ងៃទី ២៩ ខែ ធ្នូ ខាងមុខនេះ។ ដោយសារតែមូលហេតុនេះ បានជានៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលមានរយៈពេលជាងមួយខែបន្ទាប់ពីសេចក្តីសម្រេចត្រូវបានចេញ មេធាវីការពារក្តីដោយពិចារណាពីស្ថានភាព និងផលប្រយោជន៍យុត្តិធម៌ បានធ្វើស្នើសុំថា ប្រសិនបើសម្អាងហេតុនៃសេចក្តីសម្រេច នឹងមិនត្រូវបានជូនដល់គ្រប់ភាគីជាបីភាសានៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤នោះទេ អង្គជំនុំជម្រះពិសេសគួរតែជូនដល់ភាគីជាសំណៅយោគយល់ជាភាសាអង់គ្លេសតែមួយភាសាមុន[4]។ នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤

---

[1] ឯកសារ **E314/6** "បណ្តឹងជិតចិត្តរបស់ នួនជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និង ចៅក្រម យូរ ឧត្តរា" ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០១៤

[2] ឯកសារ **E314/12** "សេចក្តីសម្រេចលើបណ្តឹងជិតចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១៤ ទំព័រទី ៣។

[3] ឯកសារ **E314/12** ទំព័រទី ៣។

[4] សារអេឡិចត្រូនិចពីទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មេធាវីការពារក្តី ជូន មន្ត្រីច្បាប់របស់អង្គជំនុំជម្រះពិសេស ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤។

អង្គជំនុំជម្រះពិសេសបានបដិសេធសំណើនេះ ដោយលើកឡើងថា "វាជាការមិនត្រឹមត្រូវទេ ដែលសម្អាងហេតុនឹងត្រូវជូនតែមួយភាសាទៅភាគី។ វាចាំបាច់ត្រូវតែជាបីភាសា"[5]។ អង្គជំនុំជម្រះពិសេសក៏បានណែនាំផងដែរថា "ដោយសារស្ថានភាពនៃការបកប្រែក្នុងពេលបច្ចុប្បន្ននេះ និងការពិនិត្យមើលឡើងវិញគឺ *វាទំនងណាស់ថា [សម្អាងហេតុនេះនឹងមិនត្រូវបានចែកជូន] នៅមុនថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤នោះទេ*"[6]។

៣. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្តី បានស្នើសុំអង្គជំនុំជម្រះពិសេសសុំឲ្យពិចារណាឡើងវិញពីសេចក្តីសម្រេចរបស់ខ្លួនដែលនឹងមិនចែកជូនសំណៅឃោគយល់ជាភាសាអង់គ្លេសជាមុន។ មេធាវីការពារក្តីបានលើកឡើងថា ការធ្វើបែបនេះអាចធ្វើទៅបាននៅក្នុងករណីលើកលែង ដែលភាគីទាំងអស់មានលទ្ធភាពយល់ភាសាអង់គ្លេសបាន។ អង្គជំនុំជម្រះពិសេសក៏ធ្លាប់បានអនុញ្ញាតឲ្យមេធាវីការពារក្តី និង សហព្រះរាជអាជ្ញា ដាក់ឯកសារតែមួយភាសាក្នុងពេលដំណើរការបណ្តឹងជិតចិត្ត[7] ហើយការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការជូនសំណៅឃោគយល់ជាភាសាអង់គ្លេសតែមួយភាសាក៏ធ្លាប់មានដែរ[8]។ នៅថ្ងៃដដែល អង្គជំនុំជម្រះពិសេសបានបដិសេធសំណើនេះ ដោយសារតែចៅក្រម Downing ក៏មានមតិជំទាស់ផងដែរទៅនឹងបណ្តឹងរបស់មេធាវីការពារក្តី ខៀវ សំផន និង "ដូច្នេះហើយសម្អាងហេតុនឹងមិនចែកជូនតែភាសាអង់គ្លេសមួយបានទេ"[9]។

៤. មេធាវីការពារក្តីសូមបញ្ជាក់ថា សម្អាងហេតុនៃសេចក្តីសម្រេច និងជាពិសេសមតិជំទាស់របស់ចៅក្រម Downing គឺមានសារៈសំខាន់ណាស់សម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួន។ តែទោះជាយ៉ាងណាក៏ដោយ ដោយផ្អែកលើការណែនាំរបស់អង្គជំនុំជម្រះពិសេស គឺវាទំនងណាស់ថា មេធាវីការពារក្តីនឹង

[5] សារអេឡិចត្រូនិចពី មន្ត្រីច្បាប់របស់អង្គជំនុំជម្រះពិសេស ជូន ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មេធាវីការពារក្តី ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤។

[6] សារអេឡិចត្រូនិចពី មន្ត្រីច្បាប់របស់អង្គជំនុំជម្រះពិសេស ជូន ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មេធាវីការពារក្តី ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ (បញ្ជាក់បន្ថែម)។

[7] ឯកសារ **E314/11** "សេចក្តីសម្រេចលើសំណើបន្ទាន់បង្ខំពាក់ព័ន្ធនឹងបណ្តឹងជិតចិត្ត" ថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[8] សារអេឡិចត្រូនិចពីទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មេធាវីការពារក្តី ជូន មន្ត្រីច្បាប់របស់អង្គជំនុំជម្រះពិសេស (មានឯកសារភ្ជាប់) ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ។

[9] សារអេឡិចត្រូនិចពី មន្ត្រីច្បាប់របស់អង្គជំនុំជម្រះពិសេស ជូន ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មេធាវីការពារក្តី ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤។

មិនទទួលបានសម្អាងហេតុនេះនៅមុនថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ នោះទេ។ ហើយឧទាហរណ៍ថា បណ្តឹងសាទុក្ខនឹងត្រូវដាក់ក្នុងពេល៥ថ្ងៃ នៃថ្ងៃធ្វើការ ទោះបីជាក្នុងករណីដែលមេធាវីការពារក្តីនឹងទទួលបាននូវសម្អាងហេតុនៅថ្ងៃនេះក៏ដោយ វាក៏នឹងនៅតែមិនសមហេតុផលទេ ដែលមេធាវីការពារក្តីអាចប្រើប្រាស់អំណះអំណាងសម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួន ដោយពិចារណាចេញពីសេចក្តីសម្រេចដោយមតិភាគច្រើន និង មតិជំទាស់។ អាស្រ័យហេតុនេះហើយ នៅក្នុងកាលៈទេសៈនេះ មេធាវីការពារក្តីសូមស្នើដាក់សារណាបន្ថែមទៅលើបណ្តឹងសាទុក្ខរបស់ខ្លួន ដោយសារតែមានអំណះអំណាងបន្ថែមទៀតនៅក្នុងសម្អាងហេតុរបស់អង្គជំនុំជម្រះពិសេស។ បន្ថែមពីលើនេះ ដើម្បីឲ្យភាគីអាចពិនិត្យអំណះអំណាងបន្ថែមនេះឲ្យបានឆាប់នោះ មេធាវីការពារក្តីសូមស្នើដាក់សារណាបន្ថែមនេះតែជាភាសាអង់គ្លេសមួយជាមុន ដោយការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

៥. សម្រាប់ហេតុផលទាំងអស់នេះ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូលថា:

ក. អនុញ្ញាតឲ្យមេធាវីការពារក្តីដាក់សារណាបន្ថែមទៅលើបណ្តឹងសាទុក្ខរបស់ខ្លួន ដោយមានអំណះអំណាងបន្ថែមចេញពីសម្អាងហេតុនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពិសេស។

ខ. ចេញរយៈពេលកំណត់ចំនួន១៤ថ្ងៃ បន្ទាប់ពីការជូនដំណឹងរបស់អង្គជំនុំជម្រះពិសេសអំពីសម្អាងហេតុ សម្រាប់ការដាក់សារណាបន្ថែមនេះ និង

គ. អនុញ្ញាតឲ្យមេធាវីការពារក្តីដាក់សារណាបន្ថែមនេះតែជាភាសាអង់គ្លេសមុន ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**សហមេធាវីការពារក្តី នួន ជា**

សុន អារុណ Victor KOPPE